ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧០
ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលដីកា
លេខ ១៧ VII
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

## សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធាន
២.លោក [redacted] ចៅក្រមរបាយការណ៍
៣.លោក [redacted] ចៅក្រម
៤.លោកស្រី [redacted] ចៅក្រម
៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

-លោក [redacted]

## តំណាងមហាអយ្យការ

-ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] សុផង់ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] រីផៃ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៨៥ ក្រIII ˜ ស.អ ˜ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

ជនត្រូវចោទឈ្មោះ [redacted] រីផៃ ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររថយន្តដឹកទំនិញ ទីកន្លែងកំណើតភូមិទួលថ្ម ឃុំថ្មពួន ស្រុកព្រៃឈរ ខេត្តកំពង់ចាម លំនៅឋានមុនពេលឃាត់ខ្លួន [redacted]

Scanned with CamScanner

[redacted]ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។ (អ្នកប្ដឹងសាទុក្ខ)

មានមេធាវីការពារសិទ្ធិដោយ ៖ លោក [redacted] សុផង់

ត្រូវចោទពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ប្រព្រឹត្តនៅចំណុច ក្បែរស្រះទឹកវត្តប្រាសាទ ភូមិត្រពាំងបិទ ឃុំបឹងណាយ ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីអំឡុងខែមេសា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១៨ និង ០០ នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។

**១.អំពីអង្គហេតុៈ**

កាលពីចុងខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០ នាទី នៅត្រង់ចំណុចក្បែរស្រះទឹកវត្តប្រាសាទ ស្ថិតនៅក្នុងភូមិត្រពាំងបិទ ឃុំបឹងណាយ ស្រុកព្រៃឈរ ខេត្តកំពង់ចាម មានជនសង្ស័យឈ្មោះ [redacted]រិដែ ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពលួងលោមរួមភេទជាមួយនារីរងគ្រោះឈ្មោះ [redacted]ស្រីលក្ខ អាយុ១ ១៤ឆ្នាំ តាមរូបភាពសុំធ្វើជាសង្សារបានសម្រេចចំនួន ០៣លើក ។ លើកទី១ នៅខែមេសា ឆ្នាំ២០១៩, លើកទី២ អំឡុងដើមខែឧសភា ឆ្នាំ២០១៩, លើកទី៣ អំឡុងចុងខែឧសភា ឆ្នាំ២០១៩ និងចុងក្រោយនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១៨ និង ០០ នាទី ជនសង្ស័យឈ្មោះ [redacted]រិដែ បានលួងលោមជនរងគ្រោះយកទៅរួមភេទនៅផ្ទះដែលខ្លួនរស់ម្ដងទៀត តែពុំបានសម្រេចឡើយ ។ ក្រោយពេលកើតហេតុ ម្ដាយបង្កើតជនរងគ្រោះបានដាក់ពាក្យបណ្ដឹងមកកាន់សមត្ថកិច្ចភ្លាម សមត្ថកិច្ចបានចុះធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនសង្ស័យរួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៦៧៩ ត.ព្រ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១. មិនព្រមដោះលែងជនត្រូវចោទឈ្មោះ [redacted]រិដែ ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ ឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន តាមពាក្យសុំចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់មេធាវីការពារជនត្រូវចោទទេ ។

២. បង្គាប់ឱ្យក្រឡាបញ្ជីជូនដំណឹងទៅគ្រប់ភាគីតាមច្បាប់ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] សុផង់ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ត្រង់ចំណុចនៃសេចក្ដីសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ។

Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៨៥ ក្រ.III • ស.អ • ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១. ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៣៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុផង់ មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] រីផៃ គឺត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២. តម្កល់ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៦៧៩ ត.ព្រ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល ។

សាលដីកានេះបានប្រកាសជាអសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] សុផង់ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] រីផៃ ប្ដឹង របស់សាលាឧទ្ធរណ៍ គ្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

**២.នាពេលសវនាការ**

-បានស្ដាប់ចៅក្រមបានអានរបាយការណ៍ ។

-បានស្ដាប់តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានថា អំពីទម្រង់ច្បាប់បណ្ដឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុផង់ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] រីផៃ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ អំពីគតិច្បាប់ យល់ឃើញថាជនត្រូវចោទឈ្មោះ [redacted] រីផៃ ត្រូវបានចោទប្រកាន់ពីបទរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ គឺជាបទឧក្រិដ្ឋ ហើយការស៊ើបសួរកំពុងដំណើរការ អំពើរបស់ជនត្រូវចោទធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខនិងសណ្ដាប់ធ្នាប់ សេចក្ដីថ្លៃថ្នូររបស់សង្គមយ៉ាងធ្ងន់ធ្ងរ ដើម្បីធានា និងបង្ការកុំអោយមានការគាបសង្កត់ដល់សាក្សី និងជនរងគ្រោះជាអនីតិជន គប្បីរក្សាទុកជនត្រូវចោទអោយតុលាការអង្គសេចក្ដីចាត់ការតាមនីតិវិធីបន្ត ។ យល់ឃើញថាសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ដែលបានសម្រេចមានលក្ខណៈត្រឹមត្រូវហើយ ។ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលដីកាលេខ ៨៥ ក្រ.III ស.អ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

-ជនត្រូវចោទ [redacted] រីផៃ ឆ្លើយថា ៖ ខ្លួនមិនបានដឹងថាត្រូវបញ្ជូនមកជំនុំជម្រះនៅតុលាការកំពូលនោះទេ ព្រោះសាលាដំបូងខេត្តកំពង់ចាមបានធ្វើការជំនុំជម្រះនៅថ្ងៃទី១៥ ហើយប្រកាសទោសនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ដូច្នេះហើយខ្លួនមិនបានដឹងរឿងអ្វីនោះទេ ។

Scanned with CamScanner

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ

- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុផង់ ជាមេធាវីការពារជនត្រូវចោទឈ្មោះ [redacted] វិរៃ នៅចំពោះមុខសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុង កំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការ រៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុផង់ ជាបណ្តឹងសាទុក្ខខុសច្បាប់ ដោយហេតុថា មេធាវី [redacted] សុផង់ ធ្វើបណ្តឹងសាទុក្ខដោយឯកឯង ដោយពុំមានលិខិត ប្រគល់សិទ្ធិពីជនត្រូវចោទឈ្មោះ [redacted] វិរៃ ឱ្យខ្លួនធ្វើបណ្តឹងសាទុក្ខឡើយ ដែលវាខុសទៅនឹងបទប្បញ្ញត្តិមាត្រា ៤១៨ បញ្ញត្តអំពីបុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ និងមាត្រា ៤២២ បញ្ញត្តអំពីទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ បទប្បញ្ញត្តិមាត្រានេះ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ បានបញ្ញត្តថា "ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលត្រូវគេទាមទារក្នុងក្របខណ្ឌនីតិវិធីបត្យាប័ន អាចតំណាងដោយមេធាវី។ "*មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ*។..."

៣-យល់ឃើញថា សាលដីកាលេខ ៨៥ ក្រ॥ ស.អ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរ សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធចោលទាំងស្រុងបណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុផង់ ។

២-តម្កល់សាលដីកាលេខ ៨៥ ក្រ॥ ស.អ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល ។

Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រទី១៧ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃសុក្រ ទី២៤ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner